# សំឡេងយើង ដើម្បីសមភាពយេនឌ័រ

សំឡេង របស់យើងដើម្បី សមភាពយេនឌ័រ

**សេចក្តីថ្លែងការណ៍រួម**
**នៅក្នុងឱកាសនៃទិវានារីអន្តរជាតិឆ្នាំ២០២០ អង្គការសង្គមស៊ីវិលអំពាវនាវ**
**ឱ្យរដ្ឋាភិបាលផ្តល់អាទិភាពលើសិទ្ធិស្ត្រី**

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

នៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២០ នេះ យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមទទូចឲ្យរាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពលើសិទ្ធិស្ត្រី តាមរយៈការចាត់វិធានការបន្ទាន់និងជាក់លាក់ ក្នុងការអនុវត្តអនុសាសន៍ដែលប្រទេសកម្ពុជាបានទទួលយកក្នុងអំឡុងពេលកិច្ចប្រជុំនៃការពិនិត្យជាសកលតាមកាលកំណត់(UPR) ជុំទី៣របស់ប្រទេសកម្ពុជា និងអនុសាសន៍ដែលមានលើកឡើងនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកលើអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ស៊ី-ដ) ដែលបានចេញបន្ទាប់ពីការពិនិត្យជាទៀងទាត់លើប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩។

យើងខ្ញុំសូមស្នើឲ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ទាក់ទងនឹងប្រធានបទជាក់លាក់មួយចំនួនដូចខាងក្រោម ៖

**១) ពង្រឹងក្របខ័ណ្ឌច្បាប់ រួមមាន ៖**

ក. អនុម័តច្បាប់ប្រឆាំងការរើសអើង ដោយគ្របដណ្តប់ឲ្យបានទូលំទូលាយ ទៅលើផ្នែកនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ពូជសាសន៍ សាសនា ដោយមានកំណត់និយមន័យនៃការរើសអើងឲ្យបានច្បាស់លាស់ ទាំងការរើសអើងដោយផ្ទាល់ និងការរើសអើងដោយប្រយោលក្នុងទីសាធារណៈ និងឯកជន។

ខ. ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដើម្បីកំណត់និយមន័យ ហាមប្រាម និងដាក់ទោសទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារគ្រប់ទម្រង់រួមទាំងការរំលោភក្នុងសម្ព័ន្ធភាពប្តីប្រពន្ធ ដើម្បីសម្របសម្រួលដល់ដំណើរក្នុងការទទួលបានកិច្ចការពារ និងធានាថាជនរងគ្រោះមានលទ្ធភាពទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយជនល្មើសត្រូវបានកាត់ទោសតាមច្បាប់ ហើយនិង

គ. ធ្វើការវាយតម្លៃនូវផលប៉ះពាល់យេនឌ័រជាលក្ខណៈប្រព័ន្ធនៅពេលអនុម័តឬកែប្រែច្បាប់។

**២) ថវិកាឆ្លើយតបទៅនឹងយេនឌ័រ និងយន្តការជាតិសម្រាប់លើកកម្ពស់ស្ត្រី។** នេះរាប់បញ្ចូលទាំងការធានានូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពនិងគោលនយោបាយដើម្បីសមភាព យេនឌ័រ ទោះបីជាមានការផ្តល់ការគាំទ្រផ្នែកមូលនិធិគ្រប់គ្រាន់ពីថវិកាជាតិនិងមានយន្តការនៃការវាយតម្លៃនិងតាមដានល្អរឹងមាំហើយក៏ដោយក្តី។

៣) សេរីភាពក្នុងការបញ្ចេញមតិសម្រាប់សង្គមស៊ីវិលរួមទាំង អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ថ្នាក់ដឹកនាំសហជីព និងសកម្មជនដីធ្លី និងសកម្មជនបរិស្ថាន ហើយនិងសមាជិករបស់គណបក្សជំទាស់ ពុំត្រូវរងការឃាំឃើការត្រួតពិនិត្យ ឬការរឹតត្បិតហួសហេតុឡើយ។ ប្រជាពលរដ្ឋទូទៅត្រូវ អនុញ្ញាតដើម្បីសម្តែងពីគំនិតយោបល់ផ្ទាល់ខ្លួន ឬមានស្វ័យសម្រេចដោយខ្លួនឯង ដោយពុំមានការគំរាមកំហែង បង់ប្រាក់ពិន័យ ឬការដាក់ពន្ធនាគារឡើយ។

៤) ការអប់រំ ៖ រាប់បញ្ចូលទាំងការលុបបំបាត់ឧបសគ្គរបស់ក្មេងស្រីក្នុងការទទួលបានការអប់រំ ការលើកទឹកចិត្តដល់ស្ត្រីអោយសិក្សាអំពីវិទ្យាសាស្ត្រ ហើយនិងការបណ្តុះបណ្តាលដល់គ្រូទាំងអស់អំពីសមភាពយេនឌ័រ។

លោកអ្នក អាចស្វែងរកលទ្ធផលនៃសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការ ស៊ី-ដ ព្រមទាំងអនុសាសន៍ នៅក្នុង UPR សម្រាប់ប្រទេសកម្ពុជាជាភាសាអង់គ្លេសតាមរយៈតំណភ្ជាប់ពីរខាងក្រោម ៖

https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW%2fC%2fKHM%2fCO%2f6&Lang=en

https://lib.ohchr.org/HRBodies/UPR/Documents/Session32/KH/UPR32_Cambodia_Thematic_List_Recommendations.docx

---

**ព័ត៌មានបន្ថែម សូមទាក់ទង ៖**


លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមរយៈ០១១ ៩៤៣ ២១៣, chaksopheap@cchrcambodia.org

លោក ដានីឡូ ការស្ពេ នាយកស្តីទីនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ តាមរយៈ ០៦០ ៥០០ ០៨០, dl.caspe@ccimcambodia.org

លោកស្រី ជឹម ចាន់នាង អគ្គលេខាធិការនៃ NGO-CEDAW តាមរយៈ ០១២ ៦៦ ៨៨ ៥៣ ngocedaw.pnh@gmail.com


DCA actalliance

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ CCIM cambodian center for independent media

NGO-CEDAW